# ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន

នៅក្នុងភូមិខ្ញុំ អ្នកស្រុកមួយចំនួនតែងមានទោចក្រយាន (កង់) និង ភាគច្រើនមានទូកតូចៗ ឬ ទូកសំប៉ាននៅប្រចាំគ្រួសារផង ។ អ្នកដែលមានម៉ូតូថែមទាំងមានទូក គេរាប់ថាជាអ្នកធូរធារ ឬ អ្នកមាន ។ ឪពុកម្ដាយខ្ញុំមានទូក និង មានម៉ូតូក៏ប៉ុន្តែទូកយើងគ្មានម៉ាស៊ីនទេ[4] ។ ក្រោយមកក្នុងចុងទសវត្សរ៍ឆ្នាំ ១៩៦០ គ្រួសារណាដែលមានចាប់ពីផ្ទះឈើប្រក់ក្បឿងឡើងទៅ ហើយមានទូរទស្សន៍ មានម៉ូតូ និង ទូកម៉ាស៊ីន គ្រួសារនោះ អ្នកស្រុកឲ្យឈ្មោះថាគ្រួសារអ្នកមាន ។

---

[4] Cf. Roland Thomas, L'évolution économique du Cambodge (1900-1940), Thèse de Doctorat, Université de Paris 7, 1978, p. 142-144 (L'établissement des moyens de communications).

ភូមិស្នាយពលចែកជាពីរគឺៈ ភូមិស្នាយពលលើនៅខាងកើត និង ភូមិស្នាយពលក្រោមនៅខាងលិច ។ អ្នកភូមិស្នាយពលលើច្រើនប្រកបរបរធ្វើស្រែ ។ ពួកគាត់ចេញទៅធ្វើការតាំងពីព្រឹកព្រលឹមមុនថ្ងៃរះ ។ អ្នកស្រែច្រើនហៅរកគ្នាឲ្យជួយគ្នាទៅវិញទៅមក ។ គេប្រមូលគ្នាទាំងភូមិទៅជួយភ្ជួររាស់ដកស្ទូង ឬ ច្រូតកាត់ ។ គេជួយគ្នាម្តងម្នាក់ ដែលពួកអ្នកស្រុកហៅថាវេរប្រវាស់ដៃគ្នា ។ ជាទូទៅ គេបង្កើតបរិយាកាសសប្បាយរីករាយក្នុងការងារ ដោយមានបុរស និង ស្ត្រី ជាពិសេសកម្លោះក្រមុំ ធ្វើការផងច្រៀងតាមរបៀបចម្រៀងប្របកែផ្តោះផ្តងឆ្លើយឆ្លងគ្នាផង ដើម្បីបំបាត់ការនឿយហត់ ។ ក្រៅពីធ្វើស្រែ ប្រុសៗឡើងត្នោតយកទឹកត្នោតមកធ្វើស្ករ ឬ ធ្វើទឹកត្នោតជូរ ដែលជាភេសជ្ជៈពេញនិយមនាសម័យនោះ ។ នៅពេលទំនេររួចដៃពីស្រែចំការ ក្នុងចំណោមអ្នកស្រុកភូមិស្នាយពលលើ ពួកប្រុសៗច្រើនទៅធ្វើការជាជាងឈើ ឬ កម្មករសំណង់ នៅភូមិស្នាយពលក្រោម ព្រោះសេដ្ឋកិច្ចនៅទីនោះមានការលូតលាស់ចំរើនជឿនលឿនជាង ។ ចំណែកឯពួកស្រីៗជួយធ្វើការប្រុសៗ ដូចជាកូរស្ករ ឬ ត្បាញស្លឹកត្នោតធ្វើកន្ទេល ឬ ចាក់ស្មុកជាដើម ។

ផ្ទះសម្បែងនៅភូមិស្នាយពលលើភាគច្រើនៗធ្វើពីឈើ ឬ ឫស្សីប្រក់ស្លឹក តែគេក៏ឃើញមានផ្ទះឈើប្រក់ក្បឿងមួយៗដែរ ។ ក្នុងសម័យនោះ ពីភូមិស្នាយពលលើ ទៅភូមិស្នាយពលក្រោម មានចំងាយប្រមាណតែមួយគីឡូម៉ែត្រប៉ុណ្ណោះ ក៏ប៉ុន្តែ ចំពោះខ្ញុំដែលនៅតូច ចំងាយមួយគីឡូម៉ែត្រហាក់ដូចជាឆ្ងាយសម្បើមណាស់ ។

រវាងភូមិស្នាយពលលើ និង ភូមិស្នាយពលក្រោម ជីវភាពរស់នៅរបស់អ្នកស្រុក មានសភាពខុសគ្នាយ៉ាងដាច់ស្រឡះ ។ នៅភូមិស្នាយពលក្រោម គេឃើញមានផ្ទះឈើប្រក់ក្បឿង និង ផ្ទះថ្មមួយៗផង ។ ពាណិជ្ជករដែលមានសញ្ជាតិដើមជាជនជាតិចិន និង មន្ត្រីរាជការភាគច្រើនជាគ្រូបង្រៀនច្រើនរស់នៅភូមិស្នាយពល

ក្រោម ។ នៅក្នុងភូមិនេះ មានផ្សារមួយជាទីដែលអ្នកស្រុកមកពីភូមិជិតខាងនាំយកបន្លែ ត្រី សាច់ មកលក់ ។ ជារៀងរាល់ថ្ងៃ នៅម៉ោងប្រមាណ ៤ ឬ ៥ ទៀបភ្លឺ គេតែងឮសម្លេងជ្រូកស្រែករពោទ៍យ៉ាងទ្រហឹង កន្ទ្រាក់ស្មារតីអ្នកផងឲ្យភ្ញាក់ពីដំណេក ព្រោះចិនកាប់ជ្រូក ចាប់ផ្ដើមចាក់កជ្រូក ដើម្បីយកសាច់មកលក់នៅទីផ្សារ ។ ចិនកាប់ជ្រូកធ្វើបែបនេះ ដើម្បីបង្កកឈាមស្រស់ និង ស្ងោរចំអិនទុកលក់ ។ ចិនកាប់ជ្រូកមិនមែនលក់តែសាច់ជ្រូកប៉ុណ្ណោះទេ តែគេក៏មានលក់គ្រឿងក្នុងផងដែរ ។ ចាប់ពីម៉ោង ៥ ឡើងទៅ មនុស្សចាប់ផ្ដើមធ្វើដំណើរតាមផ្លូវធំទៅផ្សារស្នាយពលយ៉ាងគគ្រឹកគគ្រេង ។ ជាបន្តបន្ទាប់ អ្នកធ្វើដំណើរថ្មើរជើង ឬ ជិះកង់ ឬ ម៉ូតូ ដោយមានទូល ឬ ដឹកបន្លែបង្កា ត្រីសាច់ ឬ ទំនិញផ្សេងៗមកលក់មានចំនួនកាន់តែច្រើនឡើងៗ ។ អ្នកលក់រៀបចំទំនិញ បន្លែបង្កា ត្រី សាច់ សាច់ជ្រូក សាច់គោនៅលើគ្រែឫស្សី ។ ភាគច្រើន នៅផ្សារគេលក់ដូរតែម្ហូបម្ហាសំរាប់ទទួលទានតែប៉ុណ្ណោះ។ របស់របរឯទៀតដូចជា៖ ខោអាវ មុង ភួយ ប្រដាប់ប្រដាប្រើប្រាស់ ឬ ឧបករណ៍ធ្វើស្រែចំការ ត្រូវបានដាក់លក់តាមផ្ទះចិនជាហូរហែនៅតាមផ្លូវធំ ។ ផ្ទះលក់ដូររបស់របរទាំងនោះ ជារបស់ពាណិជ្ជករចិន ដែលចូលមករស់នៅក្នុងភូមិជាច្រើនជំនាន់មកហើយ ។ ចាប់ពីម៉ោង ៦ ទៅ ៧ ព្រឹកឡើងទៅ ទីផ្សារមានសភាពកុះករ និង កាន់តែកុះករឡើង ដោយសារតែពួកស្ត្រីមេផ្ទះនាំគ្នាមករកទិញបន្លែត្រីសាច់ ដើម្បីធ្វើម្ហូបប្រចាំគ្រួសារ ។ ជាធម្មតាស្ត្រីខ្មែរ ច្រើនចំណាយពេលមួយព្រឹក ឬ មួយល្ងាច ដើម្បីធ្វើម្ហូប ។ ចាប់ពីម៉ោង ៩ ព្រឹកទៅទីផ្សារត្រូវរំសាយ ហើយក្លាយទៅជាទីស្ងប់ស្ងាត់ មិនអ៊ូអរគគ្រឹកគគ្រេងដូចពេលមុនឡើយ[5] ។

---

[5] Cf. Roland Thomas, L’évolution économique du Cambodge (1900-1940), op.cit, p. 156-164 (L’organisation commerciale: le Chinois).